CITY OF LONG BEACH

សេចក្ដីប្រកាសព័ត៌មាន

PRESS RELEASE

KHMER TRANSLATION LINK គេហទំព័របកប្រែជាភាសាខ្មែរ

## សេចក្ដីប្រកាសព័ត៌មាន

ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០

ទំនាក់ទំនង : ទីក្រុងឡុងប៊ិច ចូលរួមមជ្ឈមណ្ឌលព័មាន 562.570.NEWS, jic@longbeach.gov

សម្រាប់ការបញ្ចេញព័តិមានបន្ទាន់

# ទីក្រុងឡុងប៊ិចបានចេញសេចក្ដីណែនាំ អំពីការបើកផ្លូវជិះកង់នៅឆ្នេរសមុទ្រ និងផ្លូវថ្មើរជើង មជ្ឈមណ្ឌលកីឡាវាយកូនបាល់តិននីស

ទីក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រនីញ៉ា – ថ្ងៃនេះទីក្រុងឡុងប៊ិចបានប្រកាសគោលការណ៍ ណែនាំ សម្រាប់ការឱ្យប្រើប្រាស់ផ្លូវជិះកង់នៅឆ្នេរសមុទ្រ និងផ្លូវថ្មើរជើង មជ្ឈមណ្ឌលកីឡាវាយកូនបាល់តិននីស និងទីលានវាយកូនបាល់តិននីស នៅក្នុងសួនឧទ្យាន ដែលកំពុងចាប់ផ្ដើមបើកឡើងវិញនៅ ថ្ងៃចន្ទ ទី១១ ខែឧសភា ។

អភិបាលក្រុង លោករ៉ូបើត កាស៊្យា បានមានប្រសាសន៍ថា " យើងដឹងថា សហគមន៍របស់យើង អន្ទះសារចង់ត្រឡប់ចេញទៅខាងក្រៅវិញ "។ " ខណៈពេលដែលឆ្នេរសមុទ្ររបស់យើង នៅតែត្រូវបានបិទ ដូចគ្នានឹងអ្នកទាំងអស់គ្នាដែរ ខ្ញុំកំពុងទន្ទឹងរងចាំផ្លូវជិះកង់ និងផ្លូវដើរថ្មើជើង ចាប់បើកឡើងវិញនៅថ្ងៃចន្ទ ។ សូមចងចាំថា ការអនុវត្តន៍ឃ្លាតឆ្ងាយរាងកាយពីគ្នា ធ្វើដូច្នេះយើងអាចនឹងបន្តរ ធ្វើឱ្យមានកន្លែងបើកបន្ថែមទៀត " ។

ចាប់ពីថ្ងៃទី១១ ខែឧសភា នេះ និងបន្តររហូតដល់មានការជូនដំណឹងបន្ថែមទៀត ត្រូវធ្វើតាមក្បួនសុវត្ថិភាពនៅខាងក្រោមនេះឱ្យបានខ្ជាប់ខ្ជួន ដូចជា:

## ផ្លូវជិះកង់នៅឆ្នេរសមុទ្រ និងផ្លូវថ្មើរជើង

- ត្រូវស្ថិតនៅចម្ងាយប្រាំមួយហ្វីតពីអ្នកដ៏ទៃ ដែលមិនមែនជាសមាជិកគ្រួសាររបស់អ្នក គ្រប់ពេលវេលា។
- ជៀសវាងតំបន់ណា ដែលមានមនុស្សច្រើន ។
- កុំប្រមូលផ្ដុំគ្នាជាក្រុម ឬនៅលង់លក់តែមួយកន្លែង លើកលែងតែត្រូវការសម្រាករយះពេលខ្លី ។
- តម្រូវឱ្យមានការពាក់ប្រដាប់របាំងមុខ នៅពេលមានទំនាក់ទំនងជិតស្និត ជាមួយមនុស្សផ្សេងទៀត ប៉ុន្តែមិនតម្រូវឱ្យពាក់នោះទេ ខណៈពេលហ្វឹកហ្វឺនឱ្យរាងកាយនៅឃ្លាតឆ្ងាយពីគ្នា។
- បន្ទប់ទឹកនៅឆ្នេរសមុទ្រ ឥឡូវនេះចាប់បើកវិញហើយ ។

- មាត់សមុទ្រ និងកន្លែងចំណតរថយន្តនៅឯមាត់សមុទ្រ គឺនៅតែបិទដដែល។

**មជ្ឈមណ្ឌល វាយកូនបាល់តិននីស**

- តម្រូវឱ្យអនុវត្តតាម **ក្បួនលេងកីឡាវាយកូនបាល់តិននីស នៅរាងកាយឱ្យឃ្លាតឆ្ងាយពីគ្នា** មុននឹងចាប់ផ្តើមបើកឡើងវិញ។
- ចំពោះហាង គឺអនុញ្ញាតឱ្យទៅយកឥវ៉ាន់ នៅលើចិញ្ចើមផ្លូវ ពីមុខហាងតែប៉ុណ្ណោះ។
- ភោជនីយដ្ឋាន និងតូបលក់ចំណីអាហារ គឺសម្រាប់តែការយកចេញទៅក្រៅតែប៉ុណ្ណោះ។

ចំណតរថយន្តនៅឯសួនឧទ្យាន នឹងចាប់ផ្តើមបើកឡើងវិញនៅ ថ្ងៃទី១១ ខែឧសភា ។ សួនឧទ្យានសាធារណៈ គឺបើកសម្រាប់ធ្វើចលនាសកម្មភាព តែប៉ុណ្ណោះ មានរួមទាំងការដើរ រត់ និងជិះកង់។ ការជួបជុំទំនាក់ទំនងគ្នា និងការញុំាអាហារ គឺមិនត្រូវបានអនុញ្ញាតនៅក្នុងសួនឧទ្យាន ឬកន្លែងចំណតរថយន្តនោះទេ។ ចំណតរថយន្តនៅឆ្នេរសមុទ្រ គឺនៅតែបិទរហូតដល់មានការជូនដំណឹងបន្ថែមទៀត។ អាជីវកម្មហាងលក់ទំនិញរាយ បន្ទប់លក់រថយន្ត ផ្លូវដើរ និងទីលានវាយកូនហ្គោល **បានបើកឡើងវិញនៅ ថ្ងៃទី៨ ខែឧសភា** ជាមួយការរឹតបន្តឹង និងការអនុវត្តតាមវិធីសាស្ត្រ រក្សាឱ្យមានសុវត្ថិភាពស្រដៀងគ្នា។

សកម្មភាពនេះ ត្រូវបានធ្វើឡើងដោយមន្ត្រីសុខាភិបាលទីក្រុង គឺវេជ្ជបណ្ឌិត អានីសា ដាវីស្ស Dr. Anissa Davis និងអនុលោមតាមអំណាចជាបន្ទាន់ ដែលបានផ្តល់ឱ្យប្រធានក្រុង តាមរយៈ **ការប្រកាសភាពអាសន្ននៅក្នុងតំបន់ ។**

ច្បាប់ទាំងអស់ដែលមានរួចស្រេចហើយ និងនាពេលអនាគត ចំពោះបទបញ្ជារបស់មន្ត្រីសុខាភិបាលទីក្រុង " នៅផ្ទះ មានសុវត្ថិភាព " ដែលបានគ្រោងផុតកំណត់ នៅថ្ងៃទី១៥ ខែឧសភា នឹងនៅជាធរមាន រហូតដល់មានការជូនដំណឹង ឬធ្វើច្បាប់បន្ថែមទៀត។ ទីក្រុងនឹងបន្តផ្តល់ព័ត៌មានថ្មី អំពីបទបញ្ជាទៅតាមតម្រូវការ ដើម្បីការពារសុខភាពសាធារណៈ។

សម្រាប់ព័តមានចុងក្រោយ អំពីកូវិដ-១៩ COVID-19 ជាមួយព័ត៌មានលំអិត អំពីអ្វីៗដែលទីក្រុងឡុងប៊ិច កំពុងធ្វើដើម្បីការពារសុវត្ថិភាពដល់ប្រជាជន សូមមើលក្នុងវែបសាយ : longbeach.gov/COVID19 និងតាមមើល ទីក្រុងឡុងប៊ិចនៅលើហ្វេសប៊ុក @LongBeachCity ទ្វីតទ័រ និងអិនស្ទិនក្រាម។

# # #